


*ធម្មទេសនាព្រះប្រធានសម្រាប់ឆ្នាំថ្មី*

# ប្រតិបត្តិព្រះធម៌ដោយចិត្តរីករាយ

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

**ប្រសិនបើមិនធ្វើឱ្យចិត្តខ្លួនបានត្រឹមត្រូវហើយមិនរៀនសូត្រ មិនធ្វើឱ្យគ្រួសាររុងរឿងទេ ប្រទេសជាតិក៏គ្មានសន្តិភាព ហើយពិភពលោកក៏គ្មានសន្តិភាពដែរ។**


នៅមុខរូបភ្នំអ៊ូយ៉ាម៉ាដែលកៃសូសាម៉ា នីវ៉ាណូ នីកយេ បានគូរ។

សូមជូនពរឆ្នាំថ្មី។

កូវីណានៅតែបន្តគួរឱ្យបារម្ភនៅឡើយ ក៏ប៉ុន្តែ បើមើលទៅក្នុងទីប្រជុំជន យើងឃើញថាជីវភាពធម្មតាបានត្រឡប់មក វកសភាពដើមវិញហើយ។សូមអ្នកទាំងអស់គ្នាប្រុងប្រយ័ត្នថែរក្សាខ្លួន កុំឱ្យឆ្លងមេរោគ ហើយប្រកបរបររកទទួលទានប្រចាំថ្ងៃដោយក្ដីសង្ឃឹមផងចុះ។

ការសិក្សាស្រាវជ្រាវមួយបានរកឃើញថា ដោយ សារ កូវិដ មនុស្សទាំងឡាយ នាំគ្នាចាប់ផ្ដើមចាត់ទុកគ្រួសារ សុខភាព ពេលវេលា សេចក្ដីទុកចិត្ត ថាជាកត្តាសំខាន់ ជាចំបងជាងមុនៗ។ ឆ្លងកាត់តាមការរីករាលធំឡើងៗនៃកូវិដ ១៩ មនុស្សយើងក៏ចាប់ផ្ដើមក្រឡេកភ្នែកបែរសម្លឹងមកមើលជីវិត ហើយសញ្ជឹងគិតពីជីវភាពរបស់ខ្លួន។តម្លៃសម្បទាថ្មីមួយបានកើតឡើងចំពោះរូបគេបន្តិចម្ដងៗ។យើងទាំងឡាយក៏បែបនោះដែរ តោងតែទម្លាប់ខ្លួនទៅនឹងភាពសាមញ្ញហើយផ្ចង់អារម្មណ៍ទៅតែនឹងអ្វីដែលសំខាន់ចាំបាច់ខានមិនបានតែម្យ៉ាងទើបជាការប្រសើរ។

ដោយឡែកឆ្នាំមុនយើងបានប្រឈមនឹងស្ថានភាពនយោបាយអន្តរជាតិដ៏តឹងរ៉ឹងមួយគឺការឈ្លានពានប្រទេសអ៊ុយក្រែនពីសំណាក់ប្រទេសរុស្ស៊ី។មានមនុស្សរាប់ម៉ឺននាក់បានរងគ្រោះដោយសារតែការឈ្លានពាននេះ។ខ្ញុំព្រះករុណាអាត្មាភាពសូមបួងសួងជាមួយនឹងអ្នកទាំងអស់គ្នា សុំ

ឱ្យសង្គ្រាមនេះឆាប់បានបញ្ចប់ហើយមនុស្សទាំងឡាយបានត្រឡប់ទៅរកជីវភាពស្ងប់ស្ងាត់ដូចពីមុនវិញ។ជាមួយគ្នានេះដែរខ្ញុំព្រះករុណាអាត្មាភាពក៏គិតផងដែរថាតើខ្លួនឯងអាចធ្វើអ្វីជាប្រយោជន៍ដល់មនុស្សនានាបាន ?

អ្វីដែលយើងទាំងអស់គ្នាត្រូវគិតមុនគេគឺបញ្ហា “សុខសន្តិភាពក្នុងចិត្ត” របស់យើងម្នាក់ៗ។

បើយើងគិតឱ្យស៊ីជម្រៅបន្តិចទៅ សង្គ្រាមកើតឡើងក៏ដោយសារតែចិត្តមនុស្ស។ថ្មីៗនេះយើងឧស្សាហ៍ឮពាក្យថា “ប្រទេសនោះខូច” “យើងមិនអាចអត់ឱនឱ្យជនម្នាក់នោះបានទេ”។ល។និង។ល។ អាត្មាភាពយល់ថានេះជាពាក្យដែលចេញពីបេះដូងដ៏ស្មោះត្រង់បានបទក៏ពិតមែនហើយ ក៏ប៉ុន្តែចំពោះអ្នកដែលកាន់សាសនា អ្វីដែលសំខាន់គឺត្រូវបង្វែរចិត្តមកគិតពីបេះដូងរបស់ខ្លួនឯងថាតើ “បេះដូងរបស់ខ្លួនមានសេចក្តីសុខសន្តិភាពឬទេ ?”

អ្នកដែលគិតតែប្រើពាក្យសម្តីឬក៏ធ្វើអំពើដែលនាំឱ្យអ្នកដទៃឈឺចាប់ ទោះបីជាអ្នកនោះស្រែកជំទាលឮៗពីសន្តិភាព ក៏ពាក្យសម្តីនោះមិនចូលត្រចៀកអ្នកដទៃដែរ។តោងតែដណ្តឹងសួរខ្លួនឯងដោយចោលភ្នែកមើលទៅក្នុងចិត្តខ្លួនឯងជានិច្ចជាកាលថាតើខ្លួនឯងយ៉ាងម៉េចដែរ ?តើ “បេះដូងខ្លួនមានសេចក្តីសុខសន្តិភាព” ឬទេ ?

តោងតែព្យាយាមធ្វើឱ្យបេះដូងខ្លួនឯងមានសេចក្តីសុខជានិច្ចជាកាល។សូមលើកឧទាហរណ៍មួយមកជូន។បើកភ្នែកឡើងពេលព្រឹក ពេលឃើញភ្លៀងធ្លាក់នរណាម្នាក់ក៏ច្រឡំភ្លាត់មាត់ដែរថា “ថ្ងៃនេះមេឃមិនល្អសោះរើយ” ។មនុស្សយើងតែងតែត្អូញ ត្អែរពីអ្វីៗដែលកើតឡើងនៅពីមុខខ្លួន។យើងគួរតែ

ប្តូរទម្លាប់ដែលមើលទៅអ្វីៗដោយភ្នែកអវិជ្ជមានបែបនេះ។

ទោះជានិយាយថាដូច្នេះក្តី ក៏នៅពេលដែលមានកំហឹងទៅលើអំពើអយុត្តិធម៌ដូចជាមិនអាចអត់ឱនឱ្យមនុស្សដែលបង្កសង្គ្រាម ឬមនុស្សដែលសម្លាប់មនុស្ស ឬមនុស្សដែលធ្វើឱ្យអ្នកដទៃមានរបួសផ្លូវកាយឬចិត្ត យើងតោងតែក្រឡេកមើលមកមើលខ្លួនឯងសិន ហើយប្តេជ្ញាថា “ខ្លួនមិនធ្វើទង្វើបែបនេះជាដាច់ខាត” ។នេះទើបហៅថាទង្វើនៃមនុស្សដែលមានសាសនា។

លើសពីនេះទៅទៀត អ្វីដែលសំខាន់គឺត្រូវធ្វើយ៉ាងណាអប់រំឱ្យសមាជិកគ្រួសារបានទៅជាមនុស្សល្អ ពោលគឺទៅជាមនុស្សមានអត្តចរិតល្អនៅក្នុងគ្រួសារដែលជាឯកតាតូចបំផុតនៃសង្គមឱ្យគ្រួសារបានរុង រឿងដោយថ្វាយបង្គំគោរពបូជាព្រះពុទ្ធរូបជាអាថ៌ ។

នៅក្នុងសៀវភៅដែលមានចំណងជើងថា “សាកលវិទ្យា” នៃសាសនាខុងជឺ មានល្បះមួយចែងថា “ធ្វើឱ្យបេះដូងត្រឹមត្រូវ រៀនវិជ្ជា បន្តផ្សាផ្ជាប់ទៅនឹងធ្វើឱ្យគ្រួសាររុងរឿង ធ្វើឱ្យប្រទេសជាតិនឹងនរ នឹងធ្វើឱ្យពិភពលោកមានសន្តិភាព”។ និយាយឱ្យងាយយល់ទៅ ប្រសិនបើមិនធ្វើឱ្យចិត្តខ្លួនបានត្រឹមត្រូវទេ មិនរៀនសូត្រទេ មិនធ្វើឱ្យគ្រួសាររុងរឿងទេ ប្រទេ សជាតិក៏មិនមានសន្តិភាព ហើយពិភពលោកក៏គ្មានសន្តិភាពដែរ។សូមអ្នកទាំងអស់គ្នាចារទុកងបេះដូងគ្រប់ៗគ្នា។



លើសពីនេះទៅទៀត ខ្ញុំព្រះករុណាអាត្មាភាពតែងតែបានជំរាបជាញឹកញយថា ក្នុងនាមជាជនជាតិជប៉ុនយើងតោងតែថែរក្សាប្រពៃណីជាតិយើង ធ្វើឱ្យប្រទេសជាតិយើងទៅជាប្រទេសដែលល្អស្រួលរស់នៅ ។

ប្រទេសជប៉ុនមានលក្ខណៈពិសេសមួយដែលនៅក្នុងពិភពលោកក៏មិនមានច្រើន គឺមានព្រះចៅអធិ រាជសោយរាជ្យ មានព្រះរាជវង្ស នៅជុំវិញព្រះអង្គមានប្រជារាស្ត្រដែលស្រឡាញ់រាប់អានគ្នាតាំងពីកកើតជាប្រទេសមក ហើយបង្កើតជាវប្បធម៌ដ៏សម្បូរសប្បាយថ្កុំថ្កើងមួយ។ជនជាតិជប៉ុនប្រកាន់ខ្ជាប់

នូវវប្បធម៌ខ្លួន ធ្វើឱ្យប្រទេសខ្លួនទៅជាប្រទេសល្អប្រសើរ មានគ្រឹះមាំទាំ ទោះបីជាប្រទេសជាតិធ្វើសាកលវូបនីយកម្មក្តី ក៏មានគ្រឹះមាំជាជប៉ុនដែលនាំឱ្យពិភពលោកទាំងមូលទទួលស្គាល់។

នៅជំនាន់មុនប្រទេសជប៉ុនមានឈ្មោះថា “យ៉ាម៉ាតូ” ដែលមានន័យថា “សន្តិភាពដ៏ធំធេង” ប្រកាន់ “សតិសុខដុមរមនាធំធេង” ពីដើមរហូតមក ហើយសតិនោះបានក្លាយជាឧត្តមគតិរបស់ប្រទេសជាតិជប៉ុនរៀងដរាបមក។

ព្រះអង្គម្ចាស់ហ្សូតុគី(593-622)លោកបានបញ្ចូលពាក្យថា “ប្រតិបត្តិភាពខ្ពង់ខ្ពស់ថ្លៃថ្នូរ ដោយប្រកាន់យកភាពសុខដុមរមនានិងសន្តិភាព” ដាក់ទៅក្នុងមាត្រាទី១នៃរដ្ឋធម្មនុញ្ញ១៧មាត្រាដែលលោកតាក់តែងចងក្រង។កើតជាជប៉ុនយើងតោងតែទទួលទំនៀមទម្លាប់នោះមកកាន់ហើយផ្សាយបន្តទៅជំនាន់ក្រោយទៀតធ្វើឱ្យប្រទេសជប៉ុនទៅជាប្រទេសប្រកបទៅដោយសន្តិភាព រួចហើយផ្តល់ឥទ្ធិពលទៅពិភពលោកទាំងមូលផងដែរ។

ការខិតខំពីតិចតួចនេះនឹងកើនឡើងបន្តិចម្តងៗទៅជាធំ ហើយពិភពលោកប្រកបដោយសន្តិភាពនឹងកកើតឡើង។

ជាមួយគ្នានោះដែរអ្វីដែលអាត្មាភាពចង់ឱ្យអ្នកទាំងអស់គ្នាគិតដែរនោះគឺសូមឱ្យមានចំណាប់អារម្មណ៍ទៅលើប្រទេសដែលនៅឆ្ងាយពីប្រទេសយើងបន្តទៅមុខរហូតផងដែរ។ដើម្បីឱ្យដឹងថានៅលើលោកនេះមានមនុស្សដែលជួបប្រទះការលំបាក ហើយគិតពីអ្នកទាំងនោះ ចែករំលែកទុក្ខព្រួយនិងសេចក្តីសោកសង្រេង រួចហើយធ្វើការបួងសួង បន្ទាប់មក ធ្វើសកម្មភាព។

នៅក្នុងសមាគមយើងមានគម្រោងសន្តិភាព គឺចលនាជូនអាហារមួយពេល WCRP(សន្និសិទសន្តិភាពនៃអ្នកសាសនាពិភពលោក)និងសហពន្ធសាសនាថ្មីជប៉ុនជាដើម ។យើងគួរតែចូលរួមក្នុងចលនាទាំងនេះដោយសកម្មផងដែរ។

## ជារៀងរាល់ថ្ងៃចូរយើងទាំងអស់គ្នាភ្ញាក់ឡើងរំលឹកការដឹងគុណហើយប្រតិបត្តិព្រះធម៌ដោយចិត្តរីករាយ

ឈរលើជំហរនេះ ខ្ញុំព្រះករុណាអាត្មាភាពបានដាក់ទិសដៅឆ្នាំ២០២៣នេះដូចតទៅនេះ៖

សមាគមយើងតាំងពីបង្កើតមក ចូលមកដល់ឆ្នាំនេះបានគម្រប់ខួប៨៥ឆ្នាំហើយ។ខ្ញុំព្រះករុណាសូមថ្លែងអំណរគុណជាមួយអ្នកទាំងអស់គ្នាដោយការភ្ញាក់រលឹក ហើយនឹងព្យាយាមយ៉ាងសកម្ម។

ឆ្នាំនេះក៏យើងតោងតែឃ្លាំមើលសកម្មភាពរាលដាលនៃកូរ៉ូណា ហើយឆ្លងកាត់តាមជីវភាពរាល់ថ្ងៃដែលមានជំនឿទៅលើព្រះពុទ្ធសាសនា សូមបំពេញតួនាទីក្នុងនាមជាស្វាមីភរិយា,ក្នុងនាមជាមាតាបិតា,ក្នុងនាមជាចាស់ទុំ,យើងតោងតែគិតពីការបណ្តុះណ្តាលបុត្រធិតា,កុមារនិងយុវជនដែលកំពុងតែចងក្រងអត្តចរឹតខ្លួនគេដែលជាទំពាំងស្នងឫស្សីទ្រទ្រង់សង្គមបន្តវេនពីយើង,ត្រូវធ្វើយ៉ាងណារៀបចំគ្រួសារឱ្យមានសណ្តាប់ធ្នាប់ ហើយលើសពីនេះទៅទៀត តើត្រូវធ្វើយ៉ាងណាឱ្យអ្នកទាំងនេះបន្តទំនៀមទម្លាប់នៃប្រទេសជាតិរបស់ខ្លួនឈរលើស្មារតីសុខដុមរមនា រិះគិតបែបច្នៃប្រឌិតនិងឱ្យបានហ្មត់ចត់ដើម្បីកសាងប្រទេសជាតិដ៏ល្អប្រសើរមួយ។

ដូចដែលខ្ញុំព្រះករុណាអាត្មាភាពបាននិយាយតាមសារពីឆ្នាំមុនហើយថា “ស្វាមីភរិយា” ដែលអាត្មាភាពនិយាយនេះគឺសំដៅទៅលើគូស្វាមីភរិយាក្មេងៗ, “ឪពុកម្តាយ” គឺសំដៅទៅរកអ្នកមានវ័យច្រើន

បន្តិចដែលកំពុងតែធ្វើការងារសស្រាក់សស្រាំ,រីឯអ្នកចាស់ទុំគឺអាត្មាភាពសំដៅទៅលើជំនាន់មនុស្ស ដែលមានអាយុចំណាស់មានបទពិសោធន៍ច្រើនក្នុងជីវិត ក្នុងន័យថាសូមឱ្យផ្ទេរបទពិសោធន៍ទាំងឡាយទៅកូន,ទៅចៅដើម្បីចូលរួមចំណែកក្នុងការ” បណ្តុះ

បណ្តាល□កុមារនិងយុវជនមួយជំនាន់ៗឱ្យអស់ពីសមត្ថភាពដែលជាបញ្ហាមូលដ្ឋាន មិនត្រឹមតែក្នុងសមាគមរីស្សូកូសេកៃយើងតែប៉ុណ្ណោះទេទាំងសង្គមនិងប្រទេសជាតិទាំងមូលផងដែរ។

លើសពីនេះទៅទៀតនៅក្នុងព្រួញសញ្ញានៃឆ្នាំថ្មីនេះខ្ញុំព្រះករុណាអាត្មាភាពបានបន្ថែមពាក្យមួយឃ្លាថា៖

“ខ្ញុំព្រះករុណាសូមថ្លែងអំណរគុណរួមជាមួយនឹងអ្នកទាំងអស់គ្នាដោយការភ្ញាក់រលឹក ហើយនឹងព្យាយាមយ៉ាងសកម្ម”។

និយាយថា “ពិតជាគួរឱ្យដឹងគុណណាស់” “ដោយគុណបុណ្យកុសល” ដែលជាពាក្យដឹងគុណពីក្នុងជម្រៅចិត្ត នៅពេលថ្វាយបង្គំព្រះរាល់ពេលហើយខំរស់មួយថ្ងៃឱ្យពិតជាមួយថ្ងៃ នោះគឺជាប្រភពនៃកម្លាំងចិត្តដែលផ្សាបន្តផ្ទាប់ទៅនឹងជីវិតដ៏ប្រសើរពេញចិត្ត។

យើងដឹងហើយថា ចំពោះយើងជាមនុស្ស របៀបគិតមានសារប្រយោជន៍ធំណាស់។យោលទៅតាមគំនិតដែលយើងគិត បាតុភូតដែលកើតឡើងនៅចំពោះមុខយើងនឹងប្រែប្រួលគ្មានកំណត់ទៅជាល្អឬអាក្រក់។

ដូច្នេះហើយយើងចាំបាច់តោងតែដុសខាត់ចិត្តគំនិតយើង ជាប្រចាំ ហើយសម្របសម្រួលវាឱ្យបានល្អ ជានិច្ចជាកាល។

ជានិមិត្តរូបនៅក្នុងព្រះគម្ពីរធម្មបទ មានគាថាមួយចែងថា៖
“ខ្លួនទីពឹងខ្លួន ក្រៅពីខ្លួនតើឱ្យទីពឹងអ្នកណា ដុសខាត់ចិត្តគំនិតខ្លួនដែលជាទីពឹងពំនាក់របស់ខ្លួននោះឱ្យភ្លឺថ្លាទៅ យើងក៏នឹងទៅជាទីពំនឹងពំនាក់ដ៏ចាំបាច់ខានមិនបានរបស់ខ្លួន”។



ពិតណាស់ថាធម៌របស់ព្រះពុទ្ធជាទ្រព្យដ៏ប្រសើរឧត្តុងឧត្តមដែរ។ក៏ប៉ុន្តែបើគ្រាន់តែរៀនសូត្រឱ្យត្រឹមតែចេះធម៌ទទេមិនមានប្រយោជន៍ទេតោងតែអនុវត្តជាក់ស្តែងដោយរាងកាយនិងចិត្តទើបអត្ថប្រយោជន៍ពិតនឹងបង្ហាញចេញមក។លុះដល់តំណាក់កាលអនុវត្តន៍បានទើបគេហៅថាបានរៀនសូត្រពិតប្រាកដ។

ឧបមាថា ខ្លួនឯងកំពុងតែត្រូវកិលេសមកសង្កត់ ខ្លួនតោងតែបង្ក្រាបកិលេសនោះដោយធ្វើតាមអ្វីដែលព្រះធម៌បង្រៀនមក ហើយរិះរកមាគ៌ាដែលសមស្របត្រូវនឹងខ្លួនឯង នោះទើបបានអាចហៅថា “ខ្លួនទីពឹងខ្លួន”។

ក្នុងន័យនេះដើម្បីដុសខាត់ចិត្តគំនិត យើងទាំងអស់គ្នាមានមូលដ្ឋានឥរិយាបទបី គឺ ថ្វាយបង្គំព្រះ, ណែ នាំ  ចាប់ដៃដឹកដៃ ស្តាប់ព្រះធម៌ ,និងរៀនព្រះធម៌ ក៏ពិតមែនហើយតែក៏តោងតែអានសៀវភៅដែលព្រះគ្រូទាំង ឡាយលោកសរសេរហើយយកមកតម្រង់ជាទិសដៅនិងឧត្តមគតិ ដើម្បីព្យាយាមកសាងខ្លួនឯងថែមទៀតទើបល្អ។ខ្ញុំព្រះករុណាអាត្មាភាពដើម្បីកុំឱ្យចេះតែហូរតាមទំនៀមទម្លាប់ជ្រុលពេក ក្រៅពីអានសៀវភៅព្រះពុទ្ធសាសនា ក៏មានអានសៀវភៅសាសនាខុងជឺ និងសៀវភៅផ្សេងៗទៀតរៀនសូត្រពីក្រៅបន្ថែមដែរ។ ក្រៅពីនេះចេញទៅក្នុងធម្មជាតិក៏មានន័យជ្រាលជ្រៅដែរ។រដូវ៤វិលឆ្លាស់គ្នា រុក្ខជាតិ បុប្ផាជាតិ ស្មៅ បក្សី សត្វល្អិតតែងតែប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ។

ព្រះសង្ឃខាងនិកាយសូតុស្ហូដៃហុងសាំង ខាងសមាធិហ្សេង ព្រះនាម មីយ៉ាសាគី ហិមប៉ូ ដែលមានព្រះជន្មាយុ១០៦ព្រះវស្សា ជាព្រះចៅអធិការវត្តអេយហេយជី មានព្រះពុទ្ធដីកាថា៖ អ្នកអនុវត្តសច្ចធម៌ដោយស្ងៀមស្ងាត់នោះគឺមហាធម្មជាតិ ។

យើងជាមនុស្សឯនេះរស់តែវាយតម្លៃ  អ្នកនោះអាក្រក់ សង្គមអាក្រក់ ក៏ប៉ុន្តែមនុស្សក៏ដូចធម្មជាតិដែរ អាចប្រតិបត្តិសច្ចធម៌ដោយស្ងៀមស្ងាត់ តែឯង ហើយស្រោចស្រង់ខ្លួនឯងដោយខ្លួនឯងបានទេតើ។

គេនិយាយថាចិត្តរបស់មនុស្សបានវិវត្តពីជីវភាពបែបគ្រាន់តែជាវត្ថុមានជីវិត ពីសត្វធាតុ ក្នុងរយៈពេលរាប់សិបម៉ឺនឆ្នាំទម្រាំតែអាចចេះគិតពីអ្នកដទៃ រួចមកមានមនោសញ្ចេតនា។

ជាពិសេស “ចិត្តដែលចេះសោកសង្រេង” គឺជាមនោ

សញ្ចេតនាដ៏ថ្លៃថ្លាបំផុតរបស់មនុស្ស ។ដែលហៅថាមនុស្សមានអារីយធម៌គឺមិនត្រឹមតែចេះសោកសង្រេងនៅពេលដែលគ្រួសារខ្លួនឯង បងប្អូនខ្លួនឯង កូនខ្លួនឯងមានទុក្ខទេ តែចេះសោកសង្រេងចេះមានសមានចិត្តនៅពេលដែលឃើញអ្នកដទៃ មនុស្សជាតិដូចគ្នាមានទុក្ខសោក។

នៅពេលដែលឃើញអ្នកដទៃជួបនឹងបញ្ហាហើយអ្នកក៏សោកសង្រេងយ៉ាងជ្រាលជ្រៅ នេះហើយជាទឹកចិត្តដែលផ្សាផ្ជាប់ទៅនឹងសន្តិភាពពិភពលោក។

នៅក្នុងសមាគមយើង នៅពេលដែលមាននរណាម្នាក់មានទុក្ខសោក យើងក៏បង្ហូរទឹកភ្នែកជាមួយគ្នា បន់ស្រន់ពីជម្រៅចិត្តឱ្យគេបានស្រោចស្រង់ពោលគឺចង់ប្រាប់ពីធម៌របស់ព្រះសម្មាសម្ពុទ្ធនោះឯង។នៅទីនោះគឺមានការបង្ហាញនូវមេត្តាធម៌របស់ព្រះសម្មា សម្ពុទ្ធតែម្តង។

កវីមីយ៉ាសាគី គេនជី( 1896-1933 ) ដែលមានជំនឿធម៌ជ្រាលជ្រៅទៅលើព្រះធម៌បទុមសូត្របានសរសេរថា៖ “អ្វីដែលមិនបានសុក្រឹតជាស្ថាពរ នោះគឺបានសុក្រឹតហើយ” ។អ្នកដែលរស់នៅដោយគិតថាខ្លួនមិនចេះបានសុក្រឹតសោះអ្នកនោះហើយដែលបានសុក្រឹត។

យើងទាំងអស់គ្នាក៏ដូច្នេះដែរ មិនមែននិយាយថា យល់ហើយៗទេ តែត្រូវគិតថា “មិនទាន់យល់ទេ មិនទាន់យល់ទេ” ហើយតោងតែស្រាវជ្រាវបន្តទៅមុខ ស្វែងរកមាគ៌ាជានិច្ចជាកាល ទើបប្រសើរ។ នេះគេហៅថា “ភ្ជួររាស់ស្រែបេះដូង” ។ឆ្នាំ

នេះពេញមួយឆ្នាំ ខ្ញុំព្រះករុណាអាត្មាភាព សូមឱ្យអ្នកទាំងអស់គ្នាដុសខាត់បេះដូង ថ្លែងអំណរគុណ នៅពេលដែលក្រោកពីដំណេក ហើយមានសុខភាព ល្អព្យាយាមប្រតិបត្តិព្រះធម៌ជានិច្ចជាកាលទៅមុខ។

(ដកស្រង់ចេញពីកាសែតកូសេថ្ងៃទី១ខែមករាឆ្នាំ២០២៣)



